# គោលការណ៍គ្រឹះ
# ស្តីពី
# តួនាទី របស់ មេធាវី

សមាជលើកទី៨ របស់អង្គការសហប្រជាជាតិ បានអនុម័តនូវអនុសញ្ញាស្តីពី "ការបង្កា បទឧក្រិដ្ឋនិងការពិភាក្សាលើជនប្រព្រឹត្តបទល្មើស" ដែលបានប្រព្រឹត្តឡើងនៅ ហាវ៉ាណា ( Havana) ប្រទេសគុយបា ចាប់តាំងពី ថ្ងៃទី ២៧ សីហា ដល់ ៧ កញ្ញា ១៩៩០។

នៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ ប្រជាជន ទូទាំងពិភពលោកបានបញ្ជាក់ នូវការ ប្តេជ្ញាចិត្តដើម្បីបង្កើត លក្ខខណ្ឌ ដែលស្ថិតនៅក្រោម យុត្តិធម៌ដែលអាចត្រូវបានថែរក្សា ហើយក៏ ប្រកាសជាផ្លូវការថា ជាគោលបំណងមួយដែលជាការសំរេចបាននូវសហប្រតិបត្តិការ អន្តរជាតិក្នុង ការលើកស្ទួយ និងការលើកទឹកចិត្តដល់ការ គោរពសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដែល គ្មានការខុសប្លែកគ្នាដូចជា ជាតិសាសន៍ ភេទ ភាសា រឺ សាសនា ។

សេចក្តីប្រកាសជា សាកល ក៏បានផ្ទុកនូវគោលការណ៍ សមភាព មុនច្បាប់ ការសន្មត់ថា គ្មានកំហុស សិទ្ធិចូលរួមក្នុងសវនាការ ដ៏មានយុត្តិធម៌ និងជាសាធារណៈដោយសាលាជំរះក្តី ឥត លំអៀង និងឯករាជ្យហើយនឹង ការធានារ៉ាប់រងទាំងអស់ដែលចាំបាច់សំរាប់ការការពារដល់បុគ្គល គ្រប់រូបដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ។

កតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិស៊ីវិល និងនយោបាយ បានប្រកាសបន្ថែមនូវសិទ្ធិដែល នឹងទទួលការកាត់ទោសដោយគ្មានការពន្យាពេលមិនត្រឹមត្រូវ និងសិទ្ធិចូលរួមសវនាការ ប្រកបដោយយុត្តិធម៌និងជាសាធារណៈដែលធ្វើឡើងដោយសាលាជំរះក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង ដែលបង្កើតដោយច្បាប់ ។

កតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌បានអំពាវនាវឡើងនូវ កាតព្វកិច្ចរបស់បណ្តា រដ្ឋនានាដែលស្ថិតក្រោមធម្មនុញ្ញនេះ ដើម្បីលើកស្ទួយការគោរពជា សាកល លើសិទ្ធិមនុស្សនិងសេរីភាព។

អង្គការផ្អែកលើគោលការណ៍ ការពារបុគ្គលទាំងអស់ស្ថិតក្រោមបែបណាមួយនៃការឃុំឃាំង រឺការដាក់គុកក៏បានផ្តល់អោយមនុស្សជាប់ឃុំឃាំងមានសិទ្ធិដើម្បីមានជំនួយ ហើយប្រាស្រ័យ ទាក់ទង ពិគ្រោះយោបល់នូវឱវាទផ្លូវច្បាប់ ។


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

វិធានខ្នាតគំរូអប្បរមា ចំពោះការពិភាក្សាលើជនជាប់ពន្ធនាគារ បានផ្តល់អនុសាសន៍ថា ជំនួយផ្លូវច្បាប់ និងការប្រាស្រ័យទាក់ទងដ៏លាក់ការណ៍ ដែលមានឱវាទផងដែរគួរតែត្រូវបានធានា ចំពោះជនជាប់ពន្ធនាគារមិនទាន់ទទួលការកាត់ទោស ។

សុវត្ថិភាពយាមកាមនូវការការពារដោយមានកិច្ច ធានាដែលបានប្រឈមមុខនឹងទោសប្រហារជីវិតបានបញ្ជាក់ឡើងវិញថាពិត នូវសិទ្ធិរបស់ជនគ្រប់រូបដែលត្រូវបានសង្ស័យ រឺចោទប្រកាន់ ពីបទឧក្រិដ្ឋដែលការដាក់ទោសប្រហារជីវិត អាចត្រូវបានដាក់អោយមានជំនួយច្បាប់គ្រប់គ្រាន់ និងផ្លូវការ នៅគ្រប់ដំណាក់កាលទាំងអស់នៃរឿងក្តី អនុលោមតាមមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិ ស្តីពី សិទ្ធិស៊ីវិលនិងនយោបាយ។

សេចក្តីប្រកាសស្តីពីគោលការណ៍ មូលដ្ឋានប្រកបដោយ យុត្តិធម៌ចំពោះជនរងគ្រោះដោយសារអំពើឧក្រិដ្ឋ និងការប្រើប្រាស់ មិនត្រឹមត្រូវនូវអំណាចបានផ្តល់នូវ អនុសាសន៍លើការវាស់ស្ទង់ទាំងនៅកំរិតជាតិ និងអន្តរជាតិដើម្បីបង្កើនសិទ្ធិទៅរកយុត្តិធម៌និងដំនើរការណ៍ដ៏យុត្តិធម៌ បដិទាន (ការសងវិញ) ការទូទាត់សំណង និងជំនួយដល់ជនរងគ្រោះដោយអំពើឧក្រិដ្ឋ។

ការការពារយ៉ាងគ្រប់គ្រាន់លើសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដែលបុគ្គលគ្រប់រូបដែលទទួលនូវសិទ្ធិសេដ្ឋកិច្ច សង្គម វប្បធម៌ រឺ សិទ្ធិស៊ីវិលនិងនយោបាយត្រូវការអោយមនុស្សគ្រប់រូបមានសិទ្ធិប្រកបដោយប្រសិទ្ធិភាពនូវសេវាកម្មច្បាប់ដែលត្រូវបានផ្តល់ដោយវិជ្ជាជីវៈផ្លូវច្បាប់និងមានឯករាជ្យ។

សមាគមវិជ្ជាជីវៈមេធាវីដែលមានតួនាទីដ៏សំខាន់មិនអាចខ្វះបាននៅក្នុងការគាំទ្រខ្នាតគំរូនៃវិជ្ជាជីវៈរឹង ក្រមសីលធម៌ ដែលការពារនូវសមាជិករបស់សមាគមខ្លួន ពីការធ្វើទុកបុកម្នេញ ការដាក់កំហិតមិនសមរម្យ និងការរំលោភច្បាប់ ដោយផ្តល់អោយមានសេវាកម្មច្បាប់ទៅដល់ជនគ្រប់រូបក្នុងតំរូវការហើយនឹងសហប្រតិបត្តិការជាមួយស្ថាប័នរបស់រដ្ឋាភិបាលនិងស្ថាប័នដទៃផ្សេងទៀតនៅក្នុងការបញ្ចប់នៃយុត្តិធម៌និងផលប្រយោជសាធារណៈដែលមានគោលការណ៍មូលដ្ឋានស្តីពីតួនាទីរបស់មេធាវីដែលមាននៅលំដាប់ទី៨ ខាងក្រោមហើយដែលត្រូវបានបង្កើតឡើង ដើម្បីជួយអោយរដ្ឋជាសមាជិកស្ថិតក្នុងភារកិច្ចនៃការលើកស្ទួយនិងធានាដល់តួនាទីសមរម្យរបស់មេធាវីគួរតែត្រូវបានគោរពនិងពិចារណា ដោយរដ្ឋាភិបាលនានានៅក្នុងរយៈពេលគ្រោងការងារនៃនីតិកម្មជាតិ និងនីតិវិធីតុលាការហើយគួរតែត្រូវបាននាំទៅរកការយកចិត្តទុកដាក់


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

របស់មេធាវីព្រមទាំងបុគ្គលដទៃផ្សេងទៀត ដូចជាចៅក្រម ព្រះរាជអាជ្ញា សមាជិកនៃអង្គការនីតិប្រតិបត្តិ និងនីតិបញ្ញាត្តិ និងសាធារណៈជនទូទៅ ។ គោលការណ៍ទាំងនេះនឹងស្នើសុំដល់បុគ្គលផ្សេងៗទៀតដែលអនុវត្ត មុខងារមេធាវីដែលគ្មានឋានៈផ្លូវការជាមេធាវី ។

## សិទ្ធិមានមេធាវី និងសេវាកម្មច្បាប់

១.បុគ្គលគ្រប់រូបត្រូវបានផ្តល់សិទ្ធិដើម្បីអំពាវនាវអោយមានជំនួយពីមេធាវី ដើម្បីការពារ និងបង្កើតសិទ្ធិនិងដើម្បីការពារគាត់នៅគ្រប់ដំណាក់កាលទាំងអស់នៃរឿងក្តីព្រហ្មទណ្ឌ ។

២.រដ្ឋាភិបាលនិងធានាអោយបាននូវនីតិវិធីដ៏សក្តិសិទ្ធិ និងយន្តការដែលងាយត្រួតពិនិត្យសំរាប់សិទ្ធិដ៏មានប្រសិទ្ធិភាព និងស្មើភាពក្លាយជាមេធាវី ហើយសិទ្ធិនេះត្រូវបានផ្តល់អោយដល់បុគ្គលគ្រប់រូបនៅក្នុងរយៈពេលកាន់កាប់របស់រដ្ឋាភិបាលទាំងនោះ និងកម្មវត្ថុនៃយុត្តាធិកា (ដែនសមត្ថកិច្ច ) ដូចជា ការរើសអើង ជាតិសាសន៍ ពណ៌សំប្បុរ ប្រភព ជាតិព័ន្ធ ភេទ ភាសា សាសនា មតិនយោបាយ រឺមតិផ្សេងទៀត ប្រភពជាតិ រឺសង្គម ទ្រព្យសម្បត្តិ កំនើតឋានៈសេដ្ឋកិច្ច រឺឋានៈដ៏ទៃផ្សេងទៀត ។

៣.រដ្ឋាភិបាលនិងធានាអោយបាននូវការផ្តល់អោយនូវមូលនិធិគ្រប់គ្រាន់ និងធនធានផ្សេងទៀតសំរាប់សេវាកម្មច្បាប់ដល់ជនក្រីក្រ និងបុគ្គលដែលមិនផ្តល់អត្ថប្រយោជន៍ដទៃទៀតតាមការចាំបាច់។សមាគមវិជ្ជាជីវៈមេធាវីនឹងសហប្រតិបត្តិការក្នុងអង្គការមួយនេះ ហើយការផ្តល់អោយនូវសេវាកម្មសម្បទាន និងធនធានដទៃផ្សេងទៀត ។

៤.រដ្ឋាភិបាល និងសមាគមវិជ្ជាជីវៈមេធាវីនិងលើកស្ទួយកម្មវិធីនានាដើម្បីផ្តល់ពត៌មានដល់សាធារណៈជនអំពីសិទ្ធិនិងករណីយកិច្ចរបស់ខ្លួនស្ថិតក្រោមច្បាប់ និងតួនាទីដ៏សំខាន់របស់មេធាវីនៅក្នុងការការពារសេរីភាពមូលដ្ឋានរបស់ប្រជាជន ។ ការយកចិត្តទុកដាក់ពិសេសគួរតែត្រូវបានផ្តល់ដើម្បីជួយជនក្រីក្រហើយនិងបុគ្គលដែលមិនផ្តល់អត្ថប្រយោជន៍ដទៃទៀត ដូចនេះជួយអោយគាត់អាចពោលអះអាងនូវសិទ្ធិរបស់ខ្លួន និងអំពាវនាវសុំអោយមានជំនួយពីមេធាវី ។

## ការការពារពិសេសនៅក្នុងបញ្ហាយុត្តិធម៌ នៃបទឧក្រិដ្ឋ


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

៥.រដ្ឋាភិបាលនិងធានាថាបុគ្គលគ្រប់រូបត្រូវបានផ្តល់ពត៌មានភ្លាមៗដោយ អាជ្ញាធរមានសមត្ថកិច្ចអំពីសិទ្ធិមានជំនួយពីមេធាវីម្នាក់ ដែលស្ថិតនៅលើជំរើសផ្ទាល់របស់បុគ្គលនោះ អំពីការចាប់ខ្លួន រឺឃុំខ្លួន រឺនៅពេលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ។

៦.បុគ្គលខ្លះដែលមិនមានមេធាវី នៅក្នុងគ្រប់ករណីទាំងអស់ដែលផលប្រយោជនយុត្តិធម៌តំរូវអោយមានមេធាវីដែលមានបទពិសោធន៍ និងសមត្ថកិច្ចដែលសមនឹងចរិតនៃបទល្មើស ហើយមេធាវីទាំងនោះត្រូវបានចាត់តាំងដើម្បីផ្តល់ជំនួយផ្លូវច្បាប់ដ៏មានប្រសិទ្ធិភាពដោយ គ្មានការចំណាយប្រសិនបើជនទាំងនោះខ្វះខាតនូវមធ្យោបាយគ្រប់គ្រាន់ ដើម្បីចំណាយសំរាប់សេវាកម្មរបៀបនេះ។

៧.រដ្ឋាភិបាលនឹងធានាបន្ថែមទៀតថា បុគ្គលគ្រប់រូបដែលត្រូវបានចាប់ខ្លួន រឺឃុំខ្លួន ដែលមានរឺដែលគ្មានការចោទប្រកាន់ពីបទព្រហ្មទណ្ឌ នឹងមានសិទ្ធិរហ័សតាមចិត្តមានមេធាវីក្នុងរយៈពេលមិនយឺតជាង ៤៨ ម៉ោង ចាប់ខ្លួន រឺឃាត់ខ្លួន ។

៨.គ្រប់ជនដែលត្រូវបានចាប់ខ្លួនឃាត់ខ្លួនរឺឃុំខ្លួននិងត្រូវបានផ្តល់អោយនូវឱកាសពេលវេលានិងសម្ភទានគ្រប់គ្រាន់ ដោយមេធាវីជាអ្នកប្រាស្រ័យទាក់ទងនិងជាអ្នកពិគ្រោះយោបល់ដែលគ្មានការពន្យាពេលជាមួយនិងកូនក្តីរបស់ខ្លួនដែលត្រូវធ្វើឡើងដោយលាក់ការដោយគ្មានការលួចស្តាប់ពីមន្ត្រីអនុវត្តច្បាប់ ។

## លក្ខណះសម្បត្តិ និងការ បណ្តុះបណ្តាល

៩.រដ្ឋាភិបាល សមាគមវិជ្ជាជីវៈមេធាវី និងស្ថាប័នអប់រំនិងធានាថា មេធាវីមានការអប់រំនិងបណ្តុះបណ្តាល ដ៏សមស្រប ហើយនឹងធ្វើអោយមានការយល់ដឹងអំពីឧត្តមគតិ និងករណីយកិច្ចនៃក្រមសីលធម៌មេធាវី និង អំពីសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានដែលមានការទទួលដោយច្បាប់ជាតិនិង អន្តរជាតិ។

១០.រដ្ឋាភិបាល សមាគមវិជ្ជាជីវៈមេធាវីនិងស្ថាប័នអប់រំ និងធានាថា គ្មានការរើសអើងប្រឆាំងនឹងមនុស្សជាតិដូចជា ជាតិសាសន៍ ពណ៌សំបុរ ភេទ ប្រភពជាតិព័ន្ធ សាសនា មតិនយោបាយ រឺមតិដទៃផ្សេងទៀត ប្រភពជាតិ រឺសង្គម ទ្រព្យសម្បត្តិ កំនើត ឋានៈសេដ្ឋកិច្ច រឺឋានៈដទៃផ្សេងទៀត ក្នុងរយៈពេលនៃការប្រកបវិជ្ជាជីវៈផ្លូវច្បាប់របស់គាត់លើកលែងតែតំរូវការ


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

ដែលមេធាវីត្រូវជាសញ្ជាតិមួយនៃប្រទេសមួយដែលពាក់ព័ន្ធប្រការនេះ នឹងមិនត្រូវបានចាត់ទុកថាជាការរើសអើងទេ ។

១១. នៅក្នុងប្រទេសនានាដែលក្រុមសហគម តំបន់ មានអត្ថិភាព ដែលទាំងនេះត្រូវការសេវាកម្មច្បាប់ ដោយឡែក ក្រុមរបៀបនេះមានវប្បធម៌ ប្រពៃណី រឺ ភាសា ខុសប្លែកគ្នា រឺជាជនរងគ្រោះនៃអំពើរើសអើងកាលពីអតីតកាលមុននោះ រដ្ឋាភិបាល សមាគមវិជ្ជាជីវៈមេធាវី និងស្ថាប័នអប់រំគួរតែធ្វើការវាស់ស្ទង់ពិសេសដើម្បី ផ្តល់ឱកាសអោយបេក្ខជនមកពីក្រុមទាំងនេះ ដើម្បីចូលរួមប្រកបវិជ្ជាជីវៈផ្លូវច្បាប់ និងគួរតែធានាថា គាត់នឹងទទួលបាននូវការបណ្តុះបណ្តាលដ៏សមស្របតាមតំរូវការរបស់ក្រុមទាំងនេះ ។

## ករណីយកិច្ច និងការ ទទួលខុសត្រូវ

១២. មេធាវីនឹងថែរក្សាកិត្តិយសនិងសេចក្តីថ្លៃថ្នូរគ្រប់ពេលវេលា នៃការប្រកបរបរវិជ្ជាជីវៈរបស់ខ្លួនប្រៀបដូចជាភ្នាក់ងារដ៏សារវ័ន្តនៃការគ្រប់គ្រងវិស័យយុត្តិធម៌។

១៣. ករណីយកិច្ចរបស់មេធាវីចំពោះអតិថិជនរបស់ខ្លួនរាប់បញ្ចូលរួមមានៈ

ក. ការផ្តល់ដំបូន្មានដល់អតិថិជន ដូចជាសិទ្ធិ និងកាតព្វកិច្ចផ្លូវច្បាប់របស់គាត់ ហើយនឹងដូចជាការធ្វើការអោយប្រព័ន្ធច្បាប់រហូតមកដល់ទាក់ទងនឹងសិទ្ធិនិងកាតព្វកិច្ចផ្លូវច្បាប់ របស់អតិថិជន ។

ខ. ការជួយដល់អតិថិជននៅរាល់មធ្យោបាយសមស្រប ហើយនឹងធ្វើសកម្មភាពផ្លូវច្បាប់ដើម្បីការពារផលប្រយោជន៍របស់ខ្លួន ។

គ. ការជួយអតិថិជនមុននឹងចូលដល់តុលាការ មានការជំនុំជំរក្តី រឺអាជ្ញាធររដ្ឋបាល ដោយសមស្រប ។

១៤. មេធាវីការពារសិទ្ធិរបស់អតិថិជន និងលើកស្ទួយបុព្វហេតុយុត្តិធម៌ នឹងស្វែងរកដើម្បីគាំទ្រសិទ្ធិមនុស្ស និងសេរីភាព ជាមូលដ្ឋាន មានការទទួលស្គាល់ ដោយច្បាប់ជាតិនិងអន្តរជាតិ ហើយនឹងសកម្មភាព ដោយសេរី និង ការខិតខំប្រឹងប្រែងប្រកបដោយ ភាពប្រុងប្រយ័ត្ន គ្រប់ពេលវេលា ដោយអនុលោម តាមច្បាប់និងខ្នាតគំរូដែលមានការទទួលស្គាល់និងក្រមសីលធម៌នៃវិជ្ជាជីវៈច្បាប់ ។

១៥. មេធាវីនឹងតែងតែគោរពផលប្រយោជន៍របស់អតិថិជនដោយស្វាមីភ័ក្តិ ។


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

## ការធានាអោយមានមុខងារមេធាវី

១៦.រដ្ឋាភិបាល និងធានាថា មេធាវីៈ

ក.អាចសំដែងគ្រប់មុខងារវិជ្ជាជីវៈរបស់ខ្លួន ដែលគ្មានការបំភិតបំភ័យ ការរារាំង ការរំខានរឺភាពមិនជ្រៀតជ្រែកមិនសមរម្យ។

ខ.អាចធ្វើដំនើរ និងពិគ្រោះយោបល់ជាមួយអតិថិជនរបស់ខ្លួនដោយសេរីទាំងនៅក្នុងប្រទេសផ្ទាល់និងនៅបរទេស ហើយនឹង

គ.នឹងមិនទទួលការឈឺចាប់ រឺគំរាមកំហែង ការចោទប្រកាន់ រឺទណ្ឌកម្មរដ្ឋបាល ទណ្ឌកម្មសេដ្ឋកិច្ច រឺទណ្ឌកម្មដទៃផ្សេងទៀតពីសកម្មភាពណាមួយ ដោយអនុលោមតាមករណីយកិច្ចវិជ្ជាជីវៈខ្នាតគំរូ និងក្រមសីលធម៌ ។

១៧.សន្តិសុខរបស់មេធាវី ត្រូវបានគំរាមកំហែងដោយសារលទ្ធផលនៃការរួចផុតពីមុខងាររបស់គាត់នឹងត្រូវបានការពារយ៉ាងគ្រប់គ្រាន់ដោយអាជ្ញាធរ ។

១៨.មេធាវីនឹងមិនត្រូវបានបញ្ជាក់ដល់អតិថិជន រឺបុព្វហេតុរបស់អតិថិជនរបស់ខ្លួនដែលជាលទ្ធផលនៃការរួចផុតពីតួនាទីរបស់គាត់។

១៩.គ្មាន តុលាការ រឺអាជ្ញាធររដ្ឋបាលដែលមានសិទ្ធិផ្តល់ឱវាទមុននឹងត្រូវបានទទួលស្គាល់ នឹងបដិសេធមិនទទួលស្គាល់សិទ្ធិរបស់មេធាវីដើម្បីចូលខ្លួនមុនអតិថិជនរបស់ខ្លួន វៀរលែងណាតែ មេធាវីគ្មានលក្ខណៈសម្បត្តិដោយអនុលោមតាមច្បាប់ជាតិនិងនីតិវិធីតុលាការ ។

២០.មេធាវី នឹងពេញចិត្តជាមួយអភ័យឯកសិទ្ធិ ដែលបានពីបទព្រហ្មទណ្ឌ និងស៊ីវិលសំរាប់សេចក្តីថ្លែងការណ៍ដែលទាក់ទងគ្នាដែលបានធ្វើអោយមានភាពស្មោះត្រង់ដ៏ល្អក្នុងសេចក្តីសន្និដ្ឋានការពារដោយសរសេរ រឺដោយផ្ទាល់មាត់ រឺនៅក្នុងការបង្ហាញខ្លួនតាមរយៈវិជ្ជាជីវៈរបស់ខ្លួនមុនចូលទៅតុលាការសាលាជំះក្តី រឺអាជ្ញាធរផ្លូវច្បាប់ រឺរដ្ឋបាល ។

២១.ជាករណីយកិច្ចរបស់អាជ្ញាធរមានសមត្ថកិច្ចដើម្បីធានាថា មេធាវីមានសិទ្ធិយកពត៌មានឯកសារ នៅក្នុងការកាន់កាប់របស់គាត់រឺត្រួតពិនិត្យនៅក្នុងថេរៈវេលាគ្រប់គ្រាន់ដើម្បីអោយមេធាវីអាចផ្តល់ជំនួយច្បាប់ដ៏មានប្រសិទ្ធិភាពទៅដល់អតិថិជនរបស់ខ្លួន ។ សិទ្ធិរបៀបនេះ គួរតែត្រូវបានផ្តល់អោយនូវពេលវេលាសមស្របដ៏រហ័សបំផុត ។


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

២២.រដ្ឋាភិបាលនឹងទទួលស្គាល់ និងគោរពថា ការប្រាស្រ័យទាក់ទង និងការពិគ្រោះយោបល់រវាងមេធាវី និងអតិថិជន គឺជាទំនាក់ទំនងវិជ្ជាជីវៈដ៏លាក់ការ ។

## សេរីភាព ក្នុងការបញ្ចេញមតិ និង បង្កើតសមាគម

២៣.មេធាវី ក៏ដូចជាប្រជាពលរដ្ឋដទៃទៀតដែរ គឺទទួលបាននូវសេរីភាពនៃការបញ្ចេញមតិជំនឿ បង្កើតសមាគមនិងចូលរួមប្រជុំ ។ ដោយឡែក មេធាវីនឹងមានសិទ្ធិដើម្បីចូលរួមនៅកិច្ចពិភាក្សាជាសាធារណៈរាល់បញ្ហាដែលពាក់ព័ន្ធនឹងច្បាប់ ការគ្រប់គ្រងលើវិស័យយុត្តិធម៌ និងការលើកស្ទួយ និងការពារសិទ្ធិមនុស្សហើយដើម្បីចូលរួម រឺបង្កើតអង្គការក្នុងស្រុក កំរិតជាតិ រឺអន្តរជាតិ និងចូលរួមកិច្ចប្រជុំរបស់គាត់ ។ នៅក្នុងការប្រើសិទ្ធិទាំងនេះ មេធាវីនឹងតែងតែដឹកនាំខ្លួនគាត់នៅក្នុង រង្វង់ច្បាប់ និងខ្នាតគំរូដែលមានការទទួលស្គាល់ និងក្រមសីលធម៌នៃវិជ្ជាជីវៈច្បាប់ ។

## សមាគម វិជ្ជាជីវៈមេធាវី

២៤.មេធាវីនឹងមានសិទ្ធិដើម្បីបង្កើតនិងចូលរួមសមាគមវិជ្ជាជីវៈដែលអភិបាលដោយខ្លួនឯងដើម្បីតំណាងផលប្រយោជន៍របស់ខ្លួន លើកស្ទួយការអប់រំ និងបណ្តុះបណ្តាលបន្ត ហើយនឹងការពារសីលធម៌វិជ្ជាជីវៈរបស់ខ្លួន ។ អង្គនីតិប្រតិបត្តិរបស់សមាគមវិជ្ជាជីវៈ នេះនឹងត្រូវបានបោះឆ្នោតដោយសមាជិកហើយនឹងប្រើមុខងារដែលគ្មានការជ្រៀតជ្រែកពីខាងក្រៅ ។

២៥.សមាគមវិជ្ជាជីវៈមេធាវីនឹងសហប្រតិបត្តិការជាមួយរដ្ឋាភិបាលដើម្បីធានាថា ជនគ្រប់រូបមានសិទ្ធិស្មើគ្នា និងមានប្រសិទ្ធិភាពដល់សេវាកម្មផ្លូវច្បាប់ ហើយដែលមេធាវីអាចផ្តល់ឱវាទ និងជួយដល់អតិថិជនរបស់គាត់ដោយអនុលោមតាមច្បាប់និងខ្នាតគំរូវិជ្ជាជីវៈដែលមានការទទួលស្គាល់ និងក្រមសីលធម៌ ។

## ដំណាក់កាល វិន័យ

២៦.ក្រមសីលធម៌របស់មេធាវីនឹងត្រូវបានបង្កើតដោយអង្គការច្បាប់ដ៏សមស្រប រឺនីតិបញ្ញត្តិដោយអនុលោមច្បាប់ជាតិ និងទំនៀមទំលាប់ និងខ្នាតគំរូអន្តរជាតិដែលមានការទទួលស្គាល់ និងបទដ្ឋាន ។

២៧.ពេលមានការចោទប្រកាន់រឺការប្តឹងមេធាវីទាំងនោះនឹងគោរពយ៉ាងយុត្តិធម៌តាមនីតិវិធីច្បាប់។មេធាវីមានសិទ្ធិទៅសវនាការយុត្តិធម៌មួយរាប់បញ្ចូលទាំងសិទ្ធិ មានជំនួយពីមេធាវី ។


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

២៨. ដំណាក់កាលជំរះក្តីដែលមានវិន័យប្រឆាំងមេធាវី នឹងនាំមកនូវគណៈកម្មាធិការវិន័យដ៏មិនលំអៀងត្រូវបានបង្កើតដោយវិជ្ជាជីវៈច្បាប់ មុននឹងមានអាជ្ញាធរលក្ខន្តិកៈឯករាជ្យ រឺ មុនចូលការជំនុំជំរះក្តីតាមតុលាការ និងគ្រប់គ្រងដោយការត្រួតពិនិត្យឡើងវិញរបស់តុលាកាឯករាជ្យ ។

២៩. ចំនាត់ការវិន័យ ទាំងអស់ នឹងប្តេជ្ញាចិត្តនៅក្នុងការអនុលោមតាមក្រមសីលធម៌ និងបទដ្ឋាន និងសីលធម៌វិជ្ជាជីវៈផ្លូវច្បាប់ជាមួយនឹងពន្លឺនៃគោលការទាំងនោះ ។

ប្រភព៖

បកប្រែ៖

វាយឡើងវិញ៖ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាលសំរាប់រៀបចំកាត់សេចក្តីមេដឹកនាំខ្មែរក្រហម


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល